# ការដឹកនាំអ្នកដទៃមកកាន់ព្រះយេស៊ូវគ្រីស្ទ

ជ្រើសរើសស្ថានភាពមួយនៃស្ថានភាពនានាដូចខាងក្រោម ៖

- យុវជនម្នាក់ដែលជាមិត្តរបស់អ្នក ជាសមាជិកនៃព្រះវិហារគ្រីស្ទានផ្សេង ។ នៅថ្ងៃមួយអំឡុងពេលអាហារថ្ងៃត្រង់ អ្នកទទួលអារម្មណ៍បំផុសគំនិតឲ្យនិយាយនឹងគាត់អំពីសាសនាចក្រ ។

- ខណៈពេលកំពុងដើរទៅផ្ទះវិញចេញពីសាលារៀនវិញ អ្នកបានឃើញយុវនារីម្នាក់កំពុងយំ ។ អ្នកស្គាល់ថានាងជាសមាជិកម្នាក់ក្នុងវួដរបស់អ្នក ដែលពុំបានចូលរួមក្នុងការប្រជុំអស់បីបួនឆ្នាំហើយ ។ អ្នកមានអារម្មណ៍បំផុសគំនិតឲ្យនិយាយនឹងនាង ។ នៅពេលអ្នកព្យាយាមលួងលោមនាង នាងបានប្រាប់អំពីឧបសគ្គរបស់នាង ហើយបានសួរថា « ហេតុអ្វីក៏ខ្ញុំពុំអាចមានក្ដីសប្បាយរីករាយ ? »

- ម្ដាយរបស់យុវជនម្នាក់ ដែលអ្នកស្គាល់ក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គមថ្មីៗនេះបានទទួលមរណភាព ។ អ្នកមានអារម្មណ៍បំផុសគំនិតឲ្យឆ្លើយតបចំពោះការប្រកាសព័ត៌មានដែលគាត់បានបង្ហោះថ្មីៗដូចតទៅ ៖ « មានអារម្មណ៍ឯកោណាស់ឥឡូវនេះ ។ ចង់ឲ្យមានមនុស្សម្នាក់យល់ចិត្ត » ។

នៅខាងក្រោយនៃក្រដាសមួយសន្លឹកនេះ ឬនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរនូវអ្វីដែលអ្នកនឹងនិយាយ និងធ្វើដើម្បីជួយដឹកនាំបុគ្គលនេះឲ្យមកកាន់ព្រះយេស៊ូវគ្រីស្ទ ។ នៅក្នុងការពិពណ៌នារបស់អ្នក សូមបញ្ចូលនូវចម្លើយតបនឹងសំណួរដូចខាងក្រោម ៖

- តើសេចក្ដីពិតអំពីដំណឹងល្អអ្វីខ្លះ ដែលអ្នកនឹងចែកចាយដើម្បីជួយដឹកនាំបុគ្គលនេះមកកាន់ព្រះយេស៊ូវគ្រីស្ទ ?

- តើខគម្ពីរអ្វីមួយដែលអ្នកអាចអញ្ជើញបុគ្គលនេះឲ្យសិក្សា ?

- តើអ្នកអញ្ជើញបុគ្គលនេះឲ្យធ្វើអ្វីខ្លះ ?



© 2015 by Intellectual Reserve, Inc. All rights reserved.